ព្រឹត្តិបត្រព័ត៌មាន

NEC BULLETIN

# គ.ជ.ប

## ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣

## ថ្ងៃអាទិត្យ ទី០៣ ខែមិថុនា ឆ្នាំ២០១២

លេខ ០៤ ចេញផ្សាយថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១២



សន្និសីទសារព័ត៌មានផ្សព្វផ្សាយអំពីបញ្ជីឈ្មោះបេក្ខជនផ្លូវការ និងការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត

## មាតិកា


- ជំនួបរវាង គ.ជ.ប និងសហភាពអឺរ៉ុបស្វែងយល់ពីការបោះឆ្នោត......... ២
- ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣................ ២
- បណ្ដឹងទាក់ទងនឹងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ....... ៥
- គណៈកម្មការរៀបចំការបោះឆ្នោតខេត្តបានបើកវគ្គ............................. ៦
- គ.ជ.ប កំពុងដំណើរការបោះពុម្ពសន្លឹកឆ្នោត......................................... ៩
- ចំនួនឃុំ សង្កាត់ក្នុងរាជធានី ខេត្ត ដែលគណបក្សបានចុះបញ្ជី........... ១០
- បទសម្ភាសន៍របស់ឯកឧត្តម ហាំរ៉ាណា ស៊ីរីល័យ សមាជិក គ.ជ.ប............១២
- ចម្រៀង ៖ យើងយុវវ័យត្រូវទៅបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សា......... ១៥




www.necelect.org.kh, www.voterlist.org.kh, Email: necinfo@forum.org.kh, Phone/Fax (023) 214 374

# ជំនួបរវាង គ.ជ.ប និងសហភាពអឺរ៉ុបស្វែងយល់ពីការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២




ជំនួបរវាង គ.ជ.ប និងសហភាពអឺរ៉ុប កាលពីថ្ងៃទ១១ ខែមេសា ឆ្នាំ២០១២ កន្លងទៅ

កាលពីថ្ងៃទី១១ ខែមេសា ឆ្នាំ២០១២ វេលាម៉ោង ០៩:០០នាទីព្រឹក ឯកឧត្តម អ៊ឹម សួស្ដី ប្រធានគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានអនុញ្ញាតឱ្យគណៈប្រតិភូសហភាពអឺរ៉ុបចំនួន ៥រូប ដែលដឹកនាំដោយឯកឧត្តម ហ្សង់ ហ្វ្រង់ស័រ កូតាំង (Jean-François CAUTAIN) ឯកអគ្គរដ្ឋទូត និងជាប្រធានប្រតិភូនៃសហភាពអឺរ៉ុបប្រចាំព្រះរាជាណាចក្រកម្ពុជា ចូលជួបពិភាក្សា និងស្វែងយល់អំពីការបោះឆ្នោត ជាពិសេសគឺការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ។

នៅក្នុងជំនួបនោះ ឯកឧត្តម អ៊ឹម សួស្ដី បានជម្រាបជូនភ្ញៀវអំពីការបោះឆ្នោតកន្លងមក និងការងារបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ ដែលកំពុងតែអនុវត្តនាបច្ចុប្បន្ននេះថា នៅឆ្នាំ២០១១ គ.ជ.ប បានរៀបចំការបោះឆ្នោតឡើងវិញជ្រើសរើសក្រុមប្រឹក្សាខណ្ឌពោធិ៍សែនជ័យ ដែលបានប្រព្រឹត្តទៅនៅថ្ងៃទី១១ ខែធ្នូ ឆ្នាំ២០១១ ដោយទទួលបានជោគជ័យ ។ បន្ទាប់មកនៅឆ្នាំ២០១១នេះដែរ គ.ជ.ប បានរៀបចំការពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោត និងបានផ្តល់សុពលភាពលើបញ្ជីបោះឆ្នោតឆ្នាំ២០១១ ដែលក្នុងនោះមានឈ្មោះអ្នកបោះឆ្នោតជាង ៩លាននាក់ ។ ឯកឧត្តមបានជម្រាបជូនទៀតថា សម្រាប់ឆ្នាំ២០១២នេះ គ.ជ.ប ត្រូវរៀបចំការបោះឆ្នោតបន្តបន្ទាប់ មានការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភា នីតិកាលទី៣ និងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិ ទី៣ ហើយការបោះឆ្នោតជ្រើសតាំងសមាជិកព្រឹទ្ធសភានេះបានបញ្ចប់រួចរាល់ហើយ បច្ចុប្បន្ន គ.ជ.ប កំពុងតែអនុវត្តរៀបចំការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់។

គណៈប្រតិភូបានលើកឡើងថា កាលពីឆ្នាំ២០០៨ សហភាពអឺរ៉ុបបានផ្តល់អនុសាសន៍មួយចំនួនទាក់ទងនឹងសមាសភាព គ.ជ.ប ឯករាជ្យភាពរបស់ គ.ជ.ប អំពីការប្រើប្រាស់ទម្រង់ឯកសារបញ្ជាក់អត្តសញ្ញាណ និងការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ។

ឯកឧត្តមប្រធាន គ.ជ.ប បានមានប្រសាសន៍ថា ពាក់ព័ន្ធនឹងសមាសភាព គ.ជ.ប គឺរាជរដ្ឋាភិបាលជា



ឯកឧត្តម ហ្សង់ ហ្វ្រង់ស័រ កូតាំង ឯកអគ្គរដ្ឋទូតសហភាពអឺរ៉ុប



ឯកឧត្តម អ៊ឹម សួស្តី ប្រធាន គ.ជ.ប

អ្នករៀបចំសមាសភាព រួចបញ្ជូនទៅសុំសេចក្តីទុកចិត្តពីរដ្ឋសភា ដោយពេលនោះ សមាសភាពទាំង ៩រូប របស់ គ.ជ.ប បច្ចុប្បន្ន ត្រូវបានរដ្ឋសភាផ្តល់សេចក្តីទុកចិត្តចំនួន ៩២ លើ ៩៩ សម្លេង ។ ចំពោះឯករាជ្យភាពរបស់ គ.ជ.ប ឯកឧត្តមបានបញ្ជាក់ថា នៅពេលដែលសមាសភាពទាំង ៩រូប ត្រូវបានផ្តល់សេចក្តីទុកចិត្តពីរដ្ឋសភារួចហើយ សមាសភាពទាំងអស់បានដាក់ពាក្យសុំលាឈប់ពីសមាជិកនៃគណបក្សនយោបាយ ហើយមកអនុវត្តការងាររបស់ខ្លួនតាមច្បាប់ជាធរមាន ។ រីឯការប្រើប្រាស់ឯកសារបញ្ជាក់អត្តសញ្ញាណ ដែលគេហៅថាទម្រង់ ១០១៨ នោះ កន្លងមកមានការលំបាកក្នុងការគ្រប់គ្រង ដូច្នេះក្រោយការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី៤ ឆ្នាំ២០០៨ គ.ជ.ប និងក្រសួងមហាផ្ទៃបានបង្កើតគណៈកម្មការបច្ចេកទេសមួយ ដើម្បីពិភាក្សា និងរិះរកវិធានការយ៉ាងណាដើម្បីគ្រប់គ្រងបានល្អលើការផ្តល់ទម្រង់ ១០១៨ ប៉ុន្តែនៅចុងបញ្ចប់ទម្រង់នេះគឺឈប់ឱ្យប្រើប្រាស់ ហើយ គ.ជ.ប និងក្រសួងមហាផ្ទៃបានឯកភាពគ្នាចេញលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោត និងបានចេញសេចក្តីណែនាំរួមមួយទាក់ទងនឹងការចេញលិខិតបញ្ជាក់អត្តសញ្ញាណនេះ ។ ដូច្នេះសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នេះ ប្រជាពលរដ្ឋដែលខ្វះឯកសារ ឬបាត់ឯកសារផ្លូវការសម្រាប់ចុះឈ្មោះបោះឆ្នោត ឬបោះឆ្នោត អាចទៅសុំលិខិតបញ្ជាក់អត្តសញ្ញាណសម្រាប់បម្រើឱ្យការបោះឆ្នោតនេះនៅសាលាឃុំ សង្កាត់ ដែលគាត់មានឈ្មោះក្នុងបញ្ជីបោះឆ្នោតផ្លូវការក្នុងឃុំ សង្កាត់នោះ ។ ការចេញម្តងនេះយើងគ្រប់គ្រងបានល្អ ព្រោះលិខិតបញ្ជាក់អត្តសញ្ញាណនេះមាន ២ផ្នែក គឺផ្នែកខាងក្បាល និងផ្នែកខាងចុង នៅពេលមានអ្នកស្នើសុំ គឺចេញឱ្យផ្នែកខាងចុង និងរក្សាទុកផ្នែកខាងក្បាលនៅឃុំ សង្កាត់ ។ ដោយឡែកការផ្តល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត គឺ គ.ជ.ប ធ្លាប់បានធ្វើកាលពីការបោះឆ្នោតឆ្នាំ២០០៧ និងឆ្នាំ២០០៨ ហើយប័ណ្ណនេះជួយសម្រួលឱ្យអ្នកបោះឆ្នោតបានដឹងអំពីថ្ងៃបោះឆ្នោត ការិយាល័យបោះឆ្នោត និងឯកសារដែលត្រូវប្រើនៅពេលបោះឆ្នោត ហើយទិន្នន័យដែលមាននៅក្នុងប័ណ្ណនេះ គឺយកចេញពីទិន្នន័យនៃអ្នកបោះឆ្នោតក្នុងបញ្ជីបោះឆ្នោតផ្លូវការទាំងស្រុង ។

ជាចុងបញ្ចប់ គណៈប្រតិភូបានវាយតម្លៃខ្ពស់ចំពោះ គ.ជ.ប ដែលបានខិតខំកែលម្អដើម្បីធ្វើឱ្យការបោះឆ្នោតកាន់តែមានលក្ខណៈប្រសើរឡើងថែមទៀត ។

# ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ មានបេក្ខជនឈរឈ្មោះបោះឆ្នោតសរុបចំនួន ១១១.០៥៦ នាក់

មកដល់ពេលនេះ ដំណាក់កាលចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតបានបញ្ចប់ហើយ ទន្ទឹមនឹងដំណាក់កាលឃោសនាបោះឆ្នោតកាន់តែខិតជិតចូលមកដល់ ។

តាមតារាងលទ្ធផលផ្លូវការនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ ចេញផ្សាយថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១២ ***(សូមមើលទំព័រខាងក្រោយ)*** បានបង្ហាញថា មានគណបក្សនយោបាយចំនួន ១០ បានចុះបញ្ជីបេក្ខជនឈរឈ្មោះ និងមានបេក្ខជនឈរឈ្មោះបោះឆ្នោតសរុបចំនួន ១១១.០៥៦នាក់ ក្នុងនោះស្ត្រីមានចំនួន ២៨.៤៨១នាក់ សម្រាប់ការបោះឆ្នោតនេះ ។



សន្និសីទសារព័ត៌មានកាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២

ឯកឧត្តម ហ៊ាង៉ណា ស៊ីរីល័យ សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) បានមានប្រសាសន៍នៅក្នុងសន្និសីទសារព័ត៌មាន កាលពីថ្ងៃទី១៨ ខែមេសា ឆ្នាំ២០១២ ថា គណបក្សនយោបាយទាំង ១០ នេះ មានគណបក្សប្រជាជនកម្ពុជា បានចុះបញ្ជីបេក្ខជននៅឃុំ សង្កាត់ចំនួន ១.៦៣៣ មានបេក្ខជនឈរឈ្មោះចំនួន ២៧.០១១នាក់ ក្នុងនោះមានស្ត្រីចំនួន ៦.០៦៩ នាក់។ គណបក្ស សម រង្ស៊ី បានចុះបញ្ជីបេក្ខជននៅឃុំ សង្កាត់ចំនួន ១.៦១៥ មានបេក្ខជនឈរឈ្មោះចំនួន ២៤.៨០១នាក់ ក្នុងនោះស្ត្រីមានចំនួន ៥.១៤៦នាក់ ។ គណបក្សហ៊្វុនស៊ិនប៉ិចបានចុះបញ្ជីបេក្ខជននៅឃុំ សង្កាត់ចំនួន១.៤១៣ មានបេក្ខជនឈរឈ្មោះចំនួន២០.៥៥២ នាក់ក្នុងនោះមានស្ត្រីចំនួន៦.៣០៦នាក់។គណបក្សសិទ្ធិមនុស្សបានចុះបញ្ជីបេក្ខជននៅឃុំ សង្កាត់ចំនួន ១.០៧០ មានបេក្ខជនឈរឈ្មោះចំនួន ១៦.២១៩នាក់ ក្នុងនោះមានស្ត្រីចំនួន ៣.៤៦១នាក់ ។ គណបក្សនរោត្តម រណឫទ្ធិ បានចុះបញ្ជីបេក្ខជននៅឃុំ សង្កាត់ចំនួន ១.០២៩ មានបេក្ខជនឈរឈ្មោះចំនួន ១៥.៦៧០នាក់ ក្នុងនោះមានស្ត្រីចំនួន ៤.៧៥២នាក់។ គណបក្សសញ្ជាតិកម្ពុជាបានចុះបញ្ជីបេក្ខជននៅឃុំ សង្កាត់ចំនួន ២២៥ មានបេក្ខជនឈរឈ្មោះចំនួន ៣.៥៩១នាក់ ក្នុងនោះមានស្ត្រីចំនួន១.៨១៦នាក់។គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យបានចុះបញ្ជីបេក្ខជននៅឃុំ សង្កាត់ចំនួន ១៦៤ មានបេក្ខជនឈរឈ្មោះចំនួន ២.៧១៣នាក់ ក្នុងនោះមានស្ត្រីចំនួន ៧៤៦នាក់។ គណបក្សខ្មែរឈប់ក្របានចុះបញ្ជីបេក្ខជននៅឃុំ សង្កាត់ចំនួន ២៣ មានបេក្ខជនឈរឈ្មោះចំនួន ៣៣៤នាក់ ក្នុងនោះមានស្ត្រីចំនួន ១១០នាក់ ។ គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យបានចុះបញ្ជីបេក្ខជននៅឃុំ សង្កាត់ចំនួន ៩ មានបេក្ខជនឈរឈ្មោះចំនួន ១៤១នាក់ ក្នុងនោះមានស្ត្រីចំនួន ៦៦នាក់ ។ គណបក្សចលនាប្រជាធិបតេយ្យបានចុះបញ្ជីបេក្ខជននៅឃុំសង្កាត់ចំនួន២ មានបេក្ខជនឈរឈ្មោះចំនួន ២៤នាក់ ក្នុងនោះមានស្ត្រីចំនួន ៩នាក់ ៕

# បណ្តឹងទាក់ទងនឹងការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣

នៅក្នុងដំណាក់កាលនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត មានពាក្យបណ្តឹងសរុបចំនួន ២៩បណ្តឹង ត្រូវបានប្តឹងដោយគណបក្សនយោបាយ ទៅគណៈកម្មការរាជធានីខេត្តរៀបចំការបោះឆ្នោត(គជ/ខប) ក្នុងនោះមានបណ្តឹងចំនួន ២ បានបន្តប្តឹងមក គ.ជ.ប ហើយបណ្តឹងទាំងនេះត្រូវបានដោះស្រាយចប់រួចរាល់ជាស្ថាពរ ។



លោក កែ រឹទ្ធ អនុប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្មនៃ គ.ជ.ប

ទាក់ទងនឹងបណ្តឹងនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយ លោក កែ រឹទ្ធ អនុប្រធាននាយកដ្ឋានសេវាកម្មច្បាប់ និងវិវាទកម្ម បានបញ្ជាក់បន្ថែមទៀតថា មានពាក្យបណ្តឹងសរុបចំនួន ២៩ ត្រូវបានប្តឹងទៅ គជ/ខប ហើយបណ្តឹងទាំង ២៩នេះ ត្រូវបាន គជ/ខប បើកសវនាការដោះស្រាយយល់ព្រមតាមដើមបណ្តឹងចំនួន ២១បណ្តឹង បដិសេធចំនួន ៧បណ្តឹង និងធ្វើលិខិតជូនដំណឹងបដិសេធចំនួន ១បណ្តឹង ។

ក្នុងចំណោមបណ្តឹងខាងលើមាននៅ ៖

១. ខេត្តបាត់ដំបងចំនួន ៨ បណ្តឹង ដែលប្តឹងដោយគណបក្សសិទ្ធិមនុស្ស ហើយជាលទ្ធផលត្រូវបាន គខប បាត់ដំបងបើកសវនាការយល់ព្រមតាមពាក្យបណ្តឹងចំនួន ៧បណ្តឹង និងបដិសេធចំនួន ១ បណ្តឹង ។

២. ខេត្តកំពង់ធំចំនួន ១បណ្តឹង ដែលប្តឹងដោយគណបក្សសញ្ជាតិកម្ពុជា ជាលទ្ធផល គខប កំពង់ធំបើកសវនាការសម្រេចយល់ព្រមតាមពាក្យបណ្តឹងនោះ។

៣. ខេត្តកណ្តាលចំនួន ៣បណ្តឹង ត្រូវបានប្តឹងដោយគណបក្សសញ្ជាតិកម្ពុជាចំនួន ២បណ្តឹង និងគណបក្សនរោត្តម រណឫទ្ធិចំនួន ១បណ្តឹង ហើយជាលទ្ធផលត្រូវបាន គខប កណ្តាល បើកសវនាការសម្រេចយល់ព្រមតាមពាក្យបណ្តឹងទាំងនោះ ។

៤. នៅរាជធានីភ្នំពេញមានបណ្តឹងចំនួន ១១បណ្តឹង ដែលប្តឹងដោយគណបក្សហ៊្វុនស៊ិនប៉ិចចំនួន ៦បណ្តឹង និងគណបក្សសញ្ជាតិកម្ពុជាចំនួន ៥បណ្តឹង ហើយត្រូវបាន គជប រាជធានីភ្នំពេញបើកសវនាការសម្រេចយល់ព្រមតាមពាក្យបណ្តឹងចំនួន ៩បណ្តឹង និងបដិសេធចំនួន២បណ្តឹង ជាបណ្តឹងរបស់គណបក្សហ៊្វុនស៊ិនប៉ិច ។

៥. ខេត្តព្រះវិហារមាន ១បណ្តឹង ដែលត្រូវបានប្តឹងដោយគណបក្ស សម រង្ស៊ី ជាលទ្ធផលត្រូវបាន គខប ព្រះវិហារបើកសវនាការសម្រេចបដិសេធបណ្តឹងនោះ។

៦. ខេត្តព្រះសីហនុមាន ៣បណ្តឹង ដែលប្តឹងដោយគណបក្សសិទ្ធិមនុស្ស ហើយត្រូវបាន គខប ព្រះសីហនុបើកសវនាការបដិសេធបណ្តឹងទាំង ៣នោះ ។

តទៅទំព័រទី ៨

# គណៈកម្មការរៀបចំការបោះឆ្នោតខេត្តបានបើកវគ្គបណ្តុះបណ្តាល ស្តីពីការចែកប័ណ្ណព័ត៌មានដល់ស្ថាប័នពាក់ព័ន្ធនឹងការបោះឆ្នោត

តាមប្រតិទិន ការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ចាប់ផ្តើមអនុវត្តពីថ្ងៃទី១៦ ខែមេសា រហូតដល់ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១២ ។ ដើម្បីឱ្យការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតមានភាពរលូនត្រឹមត្រូវតាមការណែនាំរបស់គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត( គ.ជ.ប) នៅតាមរាជធានី ខេត្ត គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត( គធ/ខប) បានធ្វើការបណ្តុះបណ្តាលដល់មន្ត្រីគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត( គឃ/សប) មេឃុំចៅសង្កាត់តំណាងគណបក្សនយោបាយនិងអង្គការមិនមែនរដ្ឋាភិបាល តាមប្រតិទិនរៀងៗខ្លួន ។

**- សកម្មភាពបណ្តុះបណ្តាលនៅ គខប ស្វាយរៀង ៖**



លោក សួរ្យ ទិត្យ ប្រធាន គខប ស្វាយរៀង

លោក សួរ្យ ទិត្យ ប្រធាន គខប ស្វាយរៀង បានមានប្រសាសន៍ប្រាប់ឱ្យដឹងថា ដោយអនុវត្តតាមការណែនាំរបស់ គ.ជ.ប និងប្រតិទិន គខប ស្វាយរៀង បានរៀបចំបើកវគ្គបណ្តុះបណ្តាលស្តីពីការចែកប័ណ្ណព័ត៌មានជាពីរវគ្គ ៖

- **វគ្គទី១** : បានប្រព្រឹត្តទៅនៅថ្ងៃទី០៣ ខែមេសា ឆ្នាំ២០១២ នៅសាលាគរុកោសល្យខេត្ត ដែលសិក្ខាកាមចូលរួមមាន ៖

• តំណាងអភិបាលខេត្ត តំណាងអភិបាលក្រុងស្វាយរៀង គណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាល ចៅសង្កាត់ ប្រធាន និងអនុប្រធាន ឬសមាជិក គឃ/សប ទាំងអស់ក្នុងក្រុងស្វាយរៀង និងមន្ត្រី គខប មានសិក្ខាកាមចូលរួមសរុប ៤៦ នាក់ ស្រី ០៦នាក់ ។

- **វគ្គទី២** : បានប្រព្រឹត្តទៅនៅថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១២ ។ វគ្គនេះមាន ៧មណ្ឌលប្រមូលផ្តុំ រួមមាន៖

• នៅមណ្ឌលប្រមូលផ្តុំសាលាបឋមសិក្សាបាវិត ជូនអភិបាលក្រុង ចៅសង្កាត់ ក្រុមប្រឹក្សាសង្កាត់ ប្រធាន និងអនុប្រធាន ឬសមាជិក គសប ទាំង ៥ ក្នុងក្រុងបាវិត សិក្ខាកាមចូលរួមសរុប ១៧នាក់។

• នៅមណ្ឌលប្រមូលផ្តុំសាលាបឋមសិក្សាមេសថ្ងក ជូនអភិបាលស្រុក មេឃុំ ក្រុមប្រឹក្សាឃុំ ប្រធាន និងអនុប្រធាន ឬសមាជិក គឃប ទាំង ៦ ក្នុងស្រុកចន្ទ្រា សិក្ខាកាមចូលរួមសរុប ១៦នាក់ ។

• នៅមណ្ឌលប្រមូលផ្តុំវិទ្យាល័យកំពង់ពោធិ៍ ជូនអភិបាលស្រុក មេឃុំ ក្រុមប្រឹក្សាឃុំ ប្រធាន និងអនុ



វគ្គបណ្តុះបណ្តាលនៅ គខប ស្វាយរៀង

ប្រធាន សមាជិក គឃប ទាំង ១១ ក្នុងស្រុកកំពង់ពោធិ៍ សិក្ខាកាមសរុប ៣៧នាក់ ស្រី ១នាក់ ។

- នៅមណ្ឌលប្រមូលផ្ដុំសាលាបឋមសិក្សា ហ៊ុន សែន វត្តថ្មី ជូនអភិបាលស្រុក មេឃុំ ក្រុមប្រឹក្សាឃុំ ប្រធាន និងអនុប្រធាន ឬសមាជិក គឃប ទាំង ១០ ក្នុងស្រុករំដួល សិក្ខាកាមចូលរួមសរុប ៣២នាក់ ស្រី ២នាក់ ។
- នៅមណ្ឌលប្រមូលផ្ដុំវិទ្យាល័យរមាសហែក ជូនអភិបាលស្រុក មេឃុំ ក្រុមប្រឹក្សាឃុំ ប្រធាន និងអនុប្រធាន ឬសមាជិក គឃប ទាំង១៦ ក្នុងស្រុករមាសហែក សិក្ខាកាមចូលរួមសរុប ៣៥នាក់ ស្រី១នាក់ ។
- នៅមណ្ឌលប្រមូលផ្ដុំសាលាបឋមសិក្សាស្វាយជ្រំ ជូនអភិបាលស្រុក មេឃុំ ក្រុមប្រឹក្សាឃុំ ប្រធាន និងអនុប្រធាន ឬសមាជិក គឃប ទាំង១៦ ក្នុងស្រុកស្វាយជ្រំ សិក្ខាកាមចូលរួមសរុប ៥០នាក់ ស្រី៦នាក់ ។
- នៅមណ្ឌលប្រមូលផ្ដុំសាលាបឋមសិក្សាតាន្ទូ ជូនអភិបាលស្រុក មេឃុំ ក្រុមប្រឹក្សាឃុំ ប្រធាន និងអនុប្រធាន ឬសមាជិក គឃប ទាំង៩ ក្នុងស្រុកស្វាយទាប សិក្ខាកាមចូលរួមសរុប ២៨នាក់ ។

លោក សូរ្យ ទិត្យ បានបញ្ជាក់បន្ថែមទៀតថា ផ្អែកតាមលទ្ធផល នៃការយល់ដឹងរបស់សិក្ខាកាមក្នុងពេលបណ្ដុះបណ្ដាល និងចំណាត់ការច្បាស់លាស់ សង្ឃឹមថា ការចែកប័ណ្ណព័ត៌មានអ្នកបោះឆ្នោតនាពេលខាងមុខ និងទទួលបានលទ្ធផលល្អដូចការរំពឹងទុកជាក់ជាមិនខាន ។

**- សកម្មភាពបណ្ដុះបណ្ដាលនៅ គខប កែប ៖**

ទាក់ទងនឹងការបណ្ដុះបណ្ដាលស្ដីពីការចែកប័ណ្ណព័ត៌មាននេះដែរ លោក ម៉ុក សែន ប្រធានគណៈកម្មការរៀបចំការបោះឆ្នោតខេត្តកែប( គខប ) បានមាន



លោក ម៉ុក សែន ប្រធាន គខប កែប

ប្រសាសន៍ថា សម្រាប់ខេត្តកែបបានធ្វើការបណ្ដុះបណ្ដាលកាលពីថ្ងៃទី៦ ខែមេសា ឆ្នាំ២០១២។ ដោយមានការចូលរួមពីមេភូមិ មេឃុំ ចៅសង្កាត់ តំណាងគណបក្សនយោបាយ អង្គការមិនមែនរដ្ឋាភិបាលសរុបចំនួន ៦១នាក់ ។

លោក ម៉ុក សែន បានបន្តទៀតថា ការបណ្ដុះបណ្ដាលផ្ដោតលើចំណុចសំខាន់ៗ ដូចខាងក្រោម ៖

- សេចក្ដីណែនាំស្ដីពីការផ្ដល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ។
- សេចក្ដីណែនាំរួម ស្ដីពីការផ្ដល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោត ។
- កំណត់ហេតុបូកសរុបលទ្ធផលនៃការចែកប័ណ្ណព័ត៌មានប្រចាំថ្ងៃ ។
- របាយការណ៍ស្ដីពីការផ្ដល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតតាមការិយាល័យបោះឆ្នោត។
- របាយការណ៍ស្ដីពីការផ្ដល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតក្នុងឃុំ សង្កាត់ ។
- របាយការណ៍ស្ដីពីការផ្ដល់ប័ណ្ណព័ត៌មានអ្នកបោះឆ្នោតតាមការិយាល័យបោះឆ្នោត សម្រាប់ គឃ/សប ។

**- សកម្មភាពបណ្ដុះបណ្ដាលនៅ គខប ព្រះសីហនុ ៖**

លោក ហួត ផុន ប្រធាន គខប ព្រះសីហនុ បានមានប្រសាសន៍ថា វគ្គបណ្ដុះបណ្ដាលស្ដីពីការចែក

បណ្ណព័ត៌មាន សម្រាប់ គខប ព្រះសីហនុ ត្រូវបានចែកជាពីរវគ្គ ៖

**វគ្គទី១** បានធ្វើនៅថ្ងៃទី០៥ ខែមេសា ឆ្នាំ២០១២ នៅទីស្នាក់ការ គខប ព្រះសីហនុ ដែលមានសិក្ខាកាមចំនួន ១៩នាក់ ជាមន្ត្រី គខប គ្រូបង្គោលប្រចាំក្រុង និងស្រុកទាំង ៣ ។ លោកបានបញ្ជាក់ថា ក្រោយពីបញ្ចប់វគ្គ មន្ត្រីទាំងនេះនឹងត្រូវធ្វើការបណ្តុះបណ្តាលបន្តដល់ គឃ/សប និងស្ថាប័នពាក់ព័ន្ធទៀត ។



លោក ហួត ផុន ប្រធាន គខប ព្រះសីហនុ

**វគ្គទី២** បានប្រព្រឹត្តទៅនៅថ្ងៃទី០៧ ខែមេសា ឆ្នាំ២០១២ នៅមណ្ឌលប្រមូលផ្តុំរួមមាន ៖

- វិទ្យាល័យ ហ៊ុន សែន មិត្តភាព សមាសភាពចូលរួមមាន គឃប ទាំង ៤ មកពីស្រុក ស្ទឹងហាវ និង គសប ទាំង ៥ ក្នុងក្រុងព្រះសីហនុ ដែលមានសិក្ខាកាមចូលរួមចំនួន ៣៦នាក់ ។
- សាលាស្រុកព្រៃនប់ សមាសភាពចូលរួមមាន គឃប ទាំង ១៤ ដែលមានសិក្ខាកាមចូលរួមចំនួន ៥៦នាក់ ។
- វិទ្យាល័យ ហ៊ុន សែន កំពង់សីលា សមាសភាពចូលរួមមាន គឃប ទាំង៤ និងមានសិក្ខាកាមចូលរួមចំនួន ១៦នាក់ ។

ក្រោយពីបានធ្វើការបណ្តុះបណ្តាលរួចមក យើងអាចធ្វើការសន្និដ្ឋានបានថា សិក្ខាកាមចំនួន ៩០% មានការយល់ដឹងល្អ និង១០% មានការយល់ដឹងបង្គួរ។

តមកពីទំព័រទី ៥ **បណ្តឹងទាក់ទងនឹងការចុះបញ្ជី...**

៧. ខេត្តស្វាយរៀងមានបណ្តឹងចំនួន ២បណ្តឹង ដែលប្តឹងដោយគណបក្ស សម រង្ស៊ី ចំនួន ១បណ្តឹង និងគណបក្សសិទ្ធិមនុស្សចំនួន ១បណ្តឹង ហើយបណ្តឹងទាំង ២នេះ ត្រូវបាន គខប ស្វាយរៀងសម្រេចបើកសវនាការយល់ព្រមតាមពាក្យបណ្តឹងចំនួន ១បណ្តឹង និងធ្វើលិខិតជូនដំណឹងបដិសេធ ១បណ្តឹង ជារបស់គណបក្ស សម រង្ស៊ី ។

លោក កែ រ័ត្ន បានបន្ថែមថា ក្នុងចំណោមពាក្យបណ្តឹងទាំង ២៩នេះ មាន២បណ្តឹងបានបន្តមក គ.ជ.ប គឺទី១ ជាបណ្តឹងរបស់គណបក្សសិទ្ធិមនុស្ស ដែលបានប្តឹងតវ៉ាការបដិសេធរបស់ គសប ចំការសំរោង ក្រុងបាត់ដំបង និងសេចក្តីសម្រេចរបស់ គខប បាត់ដំបង។ បណ្តឹងនេះត្រូវបាន គ.ជ.ប បើកសវនាការសង្ខេបនៅថ្ងៃទី២៧ ខែមីនា ឆ្នាំ២០១២ ដោយសម្រេចយល់ព្រមតាមដើមបណ្តឹង បង្គាប់ឱ្យ គសប ចំការសំរោង តាមរយៈ គខប បាត់ដំបង ទទួលចុះបញ្ជីបេក្ខជនតាមការទាមទាររបស់ដើមបណ្តឹង និងទី២ ជាបណ្តឹងរបស់គណបក្ស សម រង្ស៊ី នៅឃុំជាំក្សាន្ត ខេត្តព្រះវិហារ ដោយគណបក្សនេះបានប្តឹងចោទថា បេក្ខជនឈរឈ្មោះបោះឆ្នោតនៅឃុំជាំក្សាន្ត បានរងការគំរាមកំហែងជាពាក្យសម្តី មិនឱ្យឈរឈ្មោះជាបេក្ខជន ។ បណ្តឹងនេះត្រូវបាន គ.ជ.ប បើកសវនាការសង្ខេបនៅថ្ងៃទី២០ ខែមីនា ឆ្នាំ២០១២ ហើយសម្រេចបដិសេធបណ្តឹងនេះចោលដោយផ្ទុយនឹងគតិច្បាប់ ព្រោះហួសរយៈពេលកំណត់នៃការដាក់ពាក្យបណ្តឹងចំនួន ៥ថ្ងៃ ផ្ទុយនឹងបទបញ្ជា និងនីតិវិធី ដែលតម្រូវឱ្យអ្នកប្តឹងមានសិទ្ធិប្តឹងតែក្នុងរយៈពេល ៣ថ្ងៃយ៉ាងយូរបន្ទាប់ពីថ្ងៃកើតហេតុតែប៉ុណ្ណោះ ហើយបានសម្រេចស្តីបន្ទោស គឃប ជាំក្សាន្ត និង គខប ព្រះវិហារ ដែលបានដោះស្រាយពាក្យបណ្តឹងហួសរយៈពេលកំណត់ ។

# គ.ជ.ប កំពុងដំណើរការបោះពុម្ពសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោត ជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣

សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២នេះ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត(គ.ជ.ប) កំពុងបោះពុម្ពសន្លឹកឆ្នោតចំនួន **១០.៦១៩.៨៥០**សន្លឹក នៅរោងពុម្ពដែលមានទីតាំងស្ថិតនៅផ្ទះលេខ ៩ ផ្លូវ ៣៤៥ សង្កាត់បឹងកក់ទី១ ខណ្ឌទួលគោក ហើយត្រូវចំណាយទៅលើការបោះពុម្ពនេះអស់ថវិកាប្រមាណ **១,៦**លានដុល្លារអាមេរិក ។

ឯកឧត្តម ទេព នីថា អគ្គលេខាធិការ គ.ជ.ប បានមានប្រសាសន៍ថា ចំនួនសន្លឹកឆ្នោតដែលត្រូវបោះពុម្ពខាងលើនេះ មានសន្លឹកឆ្នោតគំរូ **៨១.៦៥០**សន្លឹក ។ សន្លឹកឆ្នោតសម្រាប់ប្រើក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ទាំងនេះមាន **១.៦៣៣**ប្រភេទខុសៗគ្នា ទៅតាមចំនួនគណបក្សនយោបាយដែលបានចុះបញ្ជីបេក្ខជននៅតាមគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត(គឃ/សប) និងលំដាប់លេខរៀងបញ្ជីបេក្ខជននៃគណបក្សនយោបាយដាក់នៅលើសន្លឹកឆ្នោត ។ ឯកឧត្តមបានបន្ថែមថា សន្លឹកឆ្នោតគំរូដែល គ.ជ.ប បោះពុម្ពនេះ គឺដើម្បីធ្វើជាឯកសារសម្រាប់បណ្តុះបណ្តាលដល់គណៈកម្មការរាជធានី ខេត្តរៀបចំការបោះឆ្នោត(គជ/ខប) គឃ/សប គណៈកម្មការការិយាល័យបោះឆ្នោត(គកប) និងអប់រំសាធារណជនតែប៉ុណ្ណោះ។

ឯកឧត្តមបានធ្វើការប្រៀបធៀបថា ការបោះពុម្ពសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ខុសគ្នានឹងការបោះពុម្ពសន្លឹកឆ្នោត សម្រាប់ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ ។ ការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ គឺមានសន្លឹកឆ្នោតសម្រាប់ការិយាល័យបោះឆ្នោតនីមួយៗ និងមានសន្លឹកឆ្នោតបម្រុងដែលរក្សាទុកនៅ គជ/ខប ក្នុងករណីមានបញ្ហាអ្វីមួយកើតឡើង យើងយកសន្លឹកឆ្នោតបម្រុងនេះមកប្រើជំនួស ។ ប៉ុន្តែសម្រាប់ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ មិនមានសន្លឹកឆ្នោតបម្រុងដែលរក្សាទុកនៅ គជ/ខប ឬ គឃ/សប ទេ គឺសន្លឹកឆ្នោតនេះ គ.ជ.ប ផ្តល់ទៅការិយាល័យបោះឆ្នោតតែម្តង ដែលក្នុងមួយការិយាល័យបោះឆ្នោតអាចមានសន្លឹកឆ្នោតលើសពី ៥០ ទៅ ៩៩សន្លឹក ។ ទាក់ទងនឹងសន្លឹកឆ្នោតលើសនេះ ឯកឧត្តមបានលើកឧទាហរណ៍ថា សន្លឹកឆ្នោតត្រូវបានរៀបចំចងជាសៀវភៅ ដោយក្នុងមួយសៀវភៅមាន ៥០សន្លឹក ប្រសិនបើក្នុងការិយាល័យបោះឆ្នោត១ មានអ្នកបោះឆ្នោតចំនួន ៥០០នាក់ គឺ គ.ជ.ប ត្រូវផ្តល់សន្លឹកឆ្នោត ១០សៀវភៅ ស្មើនឹង ៥០០សន្លឹក ហើយត្រូវថែម ១ដុំ ឬ ១សៀវភៅទៀត ស្មើនឹង ៥០សន្លឹក សម្រាប់បម្រុង ។ តែប្រសិនបើនៅក្នុងការិយាល័យបោះឆ្នោតនោះមានអ្នកបោះឆ្នោតចំនួន ៥០១នាក់ គ.ជ.ប ត្រូវផ្តល់សន្លឹកឆ្នោត ១១ដុំ ឬ ១១សៀវភៅ ហើយថែម១ដុំទៀត សរុបឃើញថា ការិយាល័យនោះត្រូវទទួលបានសន្លឹកឆ្នោត ១២ដុំ។ ដូច្នេះ ក្នុងករណីការិយាល័យបោះឆ្នោតមានអ្នកបោះឆ្នោត ៥០១នាក់ សន្លឹកឆ្នោតដែលលើសសម្រាប់ការិយាល័យមួយនេះគឺចំនួន ៩៩សន្លឹក ។

សូមរំលឹកថា អ្នកមានឈ្មោះក្នុងបញ្ជីបោះឆ្នោតឆ្នាំ២០១១ មានចំនួន **៩.២០៣.៤៩៣**នាក់ រីឯការិយាល័យបោះឆ្នោតមាន **១៨.១០៧** ការិយាល័យ ។

ចំពោះសន្លឹកឆ្នោតដែលត្រូវបែងចែកទៅឱ្យរាជធានី ខេត្តទាំង២៤ អាចចូលមើលក្នុងគេហទំព័រ គ.ជ.ប ដែលមានអាសយដ្ឋាន www.necelect.org.kh៕

# ចំនួនឃុំ សង្កាត់ ក្នុងរាជធានី ខេត្ត ដែលគណប
# បោះឆ្នោតជ្រើសរើសក្រុមប្រឹ

*គណបក្សនយោបាយចំនួន ១០ បានចូលរួមប្រកួតប្រជែងក្នុងការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ នៅតាមបណ្តាឃុំ សង្កាត់ នៃរាជធានី ខេត្ត ដូចតារាងខាងក្រោម ៖*

| ល.រ | រាជធានី ខេត្ត | ចំនួនឃុំ សង្កាត់ | ប្រជាជនកម្ពុជា | សម រង្ស៊ី | ហ៊្វុនស៊ិនប៉ិច | សិទ្ធិមនុស្ស | នរោត្តម រណឫ |
|---|---|---|---|---|---|---|---|
| | | | ចំនួនឃុំ សង្ | | | | |
| 1 | បន្ទាយមានជ័យ | 65 | 65 | 65 | 65 | 25 | 36 |
| 2 | បាត់ដំបង | 102 | 102 | 102 | 100 | 61 | 41 |
| 3 | កំពង់ចាម | 173 | 173 | 173 | 123 | 173 | 160 |
| 4 | កំពង់ឆ្នាំង | 69 | 69 | 69 | 69 | 69 | 69 |
| 5 | កំពង់ស្ពឺ | 87 | 87 | 87 | 77 | 86 | 78 |
| 6 | កំពង់ធំ | 81 | 81 | 81 | 80 | 42 | 71 |
| 7 | កំពត | 93 | 93 | 93 | 80 | 68 | 56 |
| 8 | កណ្តាល | 127 | 127 | 127 | 99 | 127 | 59 |
| 9 | កោះកុង | 29 | 29 | 26 | 15 | 0 | 8 |
| 10 | ក្រចេះ | 46 | 46 | 46 | 46 | 37 | 33 |
| 11 | មណ្ឌលគិរី | 21 | 21 | 21 | 19 | 1 | 1 |
| 12 | ភ្នំពេញ | 96 | 96 | 96 | 75 | 65 | 40 |
| 13 | ព្រះវិហារ | 51 | 51 | 51 | 46 | 11 | 8 |
| 14 | ព្រៃវែង | 116 | 116 | 116 | 89 | 116 | 105 |
| 15 | ពោធិ៍សាត់ | 49 | 49 | 47 | 44 | 15 | 27 |
| 16 | រតនគិរី | 50 | 50 | 38 | 32 | 0 | 2 |
| 17 | សៀមរាប | 100 | 100 | 100 | 100 | 25 | 75 |
| 18 | ព្រះសីហនុ | 27 | 27 | 27 | 25 | 2 | 15 |
| 19 | ស្ទឹងត្រែង | 34 | 34 | 34 | 20 | 0 | 14 |
| 20 | ស្វាយរៀង | 80 | 80 | 79 | 77 | 40 | 51 |
| 21 | តាកែវ | 100 | 100 | 100 | 100 | 94 | 61 |
| 22 | កែប | 5 | 5 | 5 | 3 | 0 | 0 |
| 23 | ប៉ៃលិន | 8 | 8 | 8 | 5 | 0 | 4 |
| 24 | ឧត្តរមានជ័យ | 24 | 24 | 24 | 24 | 13 | 15 |
| | **សរុបរួម** | 1,633 | 1,633 | 1,615 | 1,413 | 1,070 | 1,029 |

# ក្សបានចុះបញ្ជីបេក្ខជនឈរឈ្មោះ សម្រាប់ការ ក្សាឃុំ សង្កាត់ អាណត្តិទី៣

អាណត្តិទី៣ ឆ្នាំ២០១២ ហើយគណបក្សទាំង៨នេះបានចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោត

| ទ្ធិ | សញ្ជាតិកម្ពុជា | សម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | ខ្មែរឈប់ក្រ | សាធារណរដ្ឋប្រជាធិបតេយ្យ | ចលនាប្រជាធិបតេយ្យ | សរុបគណបក្សឈរឈ្មោះក្នុងរាជធានី ខេត្ត |
|---|---|---|---|---|---|---|
| ាត់ ដែលគណបក្សបានចុះបញ្ជីបេក្ខជនឈរឈ្មោះ | | | | | | |
| | 0 | 4 | 4 | 3 | 0 | 8 |
| | 0 | 30 | 1 | 0 | 0 | 7 |
| | 63 | 7 | 1 | 0 | 2 | 9 |
| | 6 | 2 | 1 | 2 | 0 | 9 |
| | 9 | 18 | 5 | 0 | 0 | 8 |
| | 19 | 4 | 4 | 1 | 0 | 9 |
| | 0 | 2 | 1 | 1 | 0 | 8 |
| | 47 | 10 | 3 | 0 | 0 | 8 |
| | 0 | 1 | 0 | 0 | 0 | 5 |
| | 6 | 0 | 0 | 0 | 0 | 6 |
| | 0 | 0 | 0 | 0 | 0 | 5 |
| | 10 | 1 | 1 | 0 | 0 | 8 |
| | 0 | 0 | 0 | 0 | 0 | 5 |
| | 52 | 17 | 0 | 1 | 0 | 8 |
| | 0 | 3 | 0 | 0 | 0 | 6 |
| | 0 | 0 | 0 | 0 | 0 | 4 |
| | 2 | 57 | 0 | 0 | 0 | 7 |
| | 0 | 0 | 0 | 0 | 0 | 5 |
| | 0 | 0 | 0 | 0 | 0 | 4 |
| | 5 | 0 | 2 | 0 | 0 | 7 |
| | 6 | 5 | 0 | 1 | 0 | 8 |
| | 0 | 0 | 0 | 0 | 0 | 3 |
| | 0 | 0 | 0 | 0 | 0 | 4 |
| | 0 | 3 | 0 | 0 | 0 | 6 |
| | 225 | 164 | 23 | 9 | 2 | |

# បទសម្ភាសន៍របស់ឯកឧត្តម ហាវ៉ាណ ស៊ីវិល័យ សមាជិក គ.ជ.ប ស្តីពីការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣



ឯកឧត្តម ហាវ៉ាណា ស៊ីវិល័យ សមាជិក គ.ជ.ប

*តាមច្បាប់ស្តីពីការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ និងច្បាប់ស្តីពីវិសោធនកម្មនៃច្បាប់នេះ ការឃោសនាបោះឆ្នោតមានទិសដៅឲ្យគណបក្សនយោបាយ និងបេក្ខជនឈរឈ្មោះបោះឆ្នោតធ្វើការផ្សព្វផ្សាយកម្មវិធីនយោបាយរបស់ខ្លួន ក្នុងការអភិវឌ្ឍឃុំ សង្កាត់ ជូនដល់អ្នកបោះឆ្នោត ។*

*ពាក់ព័ន្ធនឹងការឃោសនាបោះឆ្នោតនេះ កាលពីថ្ងៃទី០៦ ខែមីនា ឆ្នាំ២០១២ កម្មវិធីស្វែងយល់ពីការបោះឆ្នោតបានអញ្ជើញឯកឧត្តម ហាវ៉ាណ ស៊ីវិល័យ សមាជិកគណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត (គ.ជ.ប) ធ្វើជាវាគ្មិន ដើម្បីបកស្រាយនូវសំណួរមួយចំនួនទាក់ទងនឹងបញ្ហានេះ ហើយព្រឹត្តិបត្រព័ត៌មាន គ.ជ.ប សូមធ្វើការដកស្រង់ និងចុះផ្សាយនូវខ្លឹមសារទាំងនេះដូចខាងក្រោម ៖*

**សំណួរ ៖ *ទាក់ទងនឹងប្រធានបទពីការឃោសនានេះ សូមជម្រាបសួរឯកឧត្តមថា តើអ្វីទៅជាការឃោសនាបោះឆ្នោត ?***

**ចម្លើយ** ៖ *ការឃោសនាបោះឆ្នោតគឺជាសកម្មភាពទាំងឡាយដែលធ្វើឡើងជាសាធារណៈក្នុងក្របខណ្ឌច្បាប់បោះឆ្នោត និងបទបញ្ជា និងនីតិវិធីនៃច្បាប់បោះឆ្នោត ធ្វើក្នុងគោលដៅដើម្បីបញ្ចុះបញ្ចូលអ្នកបោះឆ្នោតឲ្យបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្សនយោបាយណាមួយ ។*

**សំណួរ ៖ *អ្វីទៅជាសកម្មភាពឃោសនាបោះឆ្នោតជាសាធារណៈ សម្រាប់បេក្ខជន ឬគណបក្សនយោបាយ?***

**ចម្លើយ** ៖ *ការដែលចាត់ទុកថាជាសកម្មភាពឃោសនាបោះឆ្នោតជាសាធារណៈមានដូចតទៅ ៖*

- *ការជួបជុំគ្នាជាសាធារណៈរបស់បេក្ខជន ឬគណបក្សនយោបាយណាមួយ*
- *ការសំដែងក្បួនដង្ហែព្យុហយាត្រា*
- *ការឃោសនាតាមផ្ទះ*
- *ការសម្តែងមតិ សំដៅស្វែងរកសម្លេងឆ្នោត*
- *ការផ្សព្វផ្សាយតាមឧគ្ឃោសនស័ព្ទ*
- *ការផ្សព្វផ្សាយតាមកាសែតវីដេអូនៅរោងវីដេអូសាធារណៈ ឬនៅទីធ្លាសាធារណៈ*
- *ការបិទផ្សាយនូវរូបភាពឃោសនាតាមទីសាធារណៈ*
- *ការចែកខិត្តប័ណ្ណគណបក្សនយោបាយ ដើម្បីឲ្យអ្នកបោះឆ្នោតយល់ដឹងពីគោលនយោបាយរបស់បេក្ខជន និងគណបក្សនយោបាយ*
- *ការចែកចាយសម្លៀកបំពាក់ មួក ឬអាវយឺត ដែល*

មានសរសេរ គូស គោលដៅ សរសេរជាសញ្ញាដើម្បី បញ្ជាក់នូវគោលដៅរបស់គណបក្ស និងបេក្ខជន

- ការលើកបដាជាសារធារណៈ ឬលើកស្លាក ដើម្បី សរសេរនូវគោលនយោបាយរបស់បេក្ខជន ឬ គណបក្សនយោបាយណាមួយ
- ការប្រគំតន្ត្រីដោយដើរជាក្បួន ឬច្រៀងចម្រៀង ឃោសនា ការលេងភ្លេងឃោនាបោះឆ្នោត ដើម្បី ផ្សព្វផ្សាយឲ្យអ្នកបោះឆ្នោតគាំទ្របេក្ខជន ឬគណបក្ស នយោបាយ ។

**សំណួរ ៖ *សូមជម្រាបឯកឧត្តម តើការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣ ឆ្នាំ២០១២ មានរយៈពេលប៉ុន្មានថ្ងៃ ហើយសកម្មភាពនៃការឃោសនាបោះឆ្នោតហ្នឹង ចាប់ផ្តើមពីថ្ងៃណាដល់ថ្ងៃណាដែរ ?***

**ចម្លើយ** ៖ ការបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី៣នេះ មានរយៈពេល ១៥ថ្ងៃ គឺចាប់ពីថ្ងៃទី១៨ ខែឧសភា ដល់ថ្ងៃទី០១ ខែមិថុនា ឆ្នាំ ២០១២ ។ គណបក្សនយោបាយអាចធ្វើការឃោសនា ចាប់ពីម៉ោង ៦:០០នាទីព្រឹក រហូតដល់ម៉ោង ១០:០០ នាទីយប់ រៀងរាល់ថ្ងៃ ។ ហើយចាប់ពីម៉ោង ១០:០០ នាទីយប់ រហូតដល់ម៉ោង ៦:០០នាទីព្រឹក គណបក្សត្រូវផ្អាកសកម្មភាពឃោសនារបស់ខ្លួន ដើម្បីកុំឲ្យរំខានដល់ប្រជាជនគេសម្រាក ។ ម្យ៉ាងទៀត រាល់សកម្មភាពឃោសនាដោយប្រើសម្លេងបំពងនៅពេលថ្ងៃ គឺចាប់ពីថ្ងៃត្រង់ម៉ោង ១២:០០នាទី ដល់ម៉ោង ២:០០នាទីរសៀល ក៏ត្រូវផ្អាកដែរ គឺសម្រាកដែរ ។ ហើយការឃោសនាបោះឆ្នោតត្រូវបញ្ចប់ក្នុងរយៈពេល ២៤ម៉ោង មុនថ្ងៃបោះឆ្នោត ។

**សំណួរ ៖ *តើក្នុងអំឡុងពេលនៃការឃោសនាបោះឆ្នោតហ្នឹង មុននឹងធ្វើសកម្មភាពឃោសនាបោះឆ្នោត តើគណបក្សនយោបាយនីមួយៗត្រូវធ្វើដូចម្តេច?***

**ចម្លើយ** ៖ មុននឹងធ្វើការឃោសនាបោះឆ្នោត គណបក្សនយោបាយ ឬបេក្ខជន ត្រូវជូនដំណឹងជាមុន ជាលាយលក្ខណ៍អក្សរមកគណៈកម្មការឃុំ សង្កាត់រៀបចំការបោះឆ្នោត ហៅកាត់ថា គឃ/សប ដើម្បីសម្របសម្រួលរៀបចំការពារសន្តិសុខ និងចៀសវាងការឃោសនាជាន់គ្នា ឬប៉ះទង្គិចគ្នា ។ ក្នុងករណីគណបក្សនយោបាយ ឬបេក្ខជនណាដែលមានបំណងជួលរោងមហោស្រព ទីលានកីឡា ឬក៏ទីសាធារណៈ ឬក៏កន្លែងឯកជនត្រូវសុំទៅអ្នកដែលគ្រប់គ្រងទីកន្លែងនោះ ០៣ថ្ងៃ មុនថ្ងៃឃោសនា ហើយត្រូវចម្លងពាក្យសុំ ១ច្បាប់ ទៅ គឃ/សប ដើម្បីគាត់រៀបចំការងាររបស់គាត់ដែរ ពីព្រោះថា ធម្មតាការឃោសនាមានច្រើនគណបក្ស ដូច្នេះទៅតាមលំដាប់ ហើយពេលដែលបានដាក់ពាក្យហើយ អ្នកទទួលខុសត្រូវគ្រប់គ្រងកន្លែងហ្នឹង ត្រូវឆ្លើយនឹងសំណើរបស់គាត់ក្នុងរយៈពេល ២៤ម៉ោង ពេលគាត់ទទួលបានការអនុញ្ញាត បេក្ខជន ឬគណបក្សនយោបាយ ត្រូវជូនដំណឹងជាលាយលក្ខណ៍អក្សរទៅ គឃ/សប ដើម្បីឲ្យគាត់រៀបចំសហការជាមួយនឹងអ្នកគ្រប់គ្រងទីកន្លែង ដើម្បីរក្សាសន្តិសុខ សុវត្ថិភាពអ្នកដែលធ្វើការឃោសនា។ ក្នុងករណីគណបក្សនយោបាយហែក្បួនធ្វើយុទ្ធនាការឃោសនាបោះឆ្នោតរួមគ្នាច្រើនឃុំ សង្កាត់ គណបក្សនយោបាយត្រូវជូនដំណឹងទៅ គឃ/សប ដែលក្បួនរបស់គាត់ត្រូវឆ្លងកាត់ យ៉ាងហោចណាស់ឲ្យបាន ០៣ ថ្ងៃមុនថ្ងៃហែក្បួន ទៅសមត្ថកិច្ចដើម្បីរៀបចំការពារសន្តិសុខ សុវត្ថិភាព ។

**សំណួរ ៖ *ក្នុងការឃោសនាបោះឆ្នោត កត្តាអ្វីខ្លះដែលត្រូវហាមឃាត់ចំពោះមន្ត្រីរាជការ និងមន្ត្រីដែលកំពុងបំពេញភារកិច្ចនោះ ?***

**ចម្លើយ** ៖ នៅក្នុងការឃោសនាបោះឆ្នោត មន្ត្រីរាជការស៊ីវិល អាជ្ញាធរដែនដីគ្រប់លំដាប់ថ្នាក់ កងរាជអាវុធហត្ថ នគរបាលជាតិ និងមន្ត្រីតុលាការ ដែលកំពុង

បំពេញភារកិច្ច ៖

- មិនត្រូវប្រើឥទ្ធិពល អំណាច នៃតួនាទីរបស់ខ្លួន ដោយប្រយោល ឬចំពោះទៅលើដំណើរការឃោសនាបោះឆ្នោតឡើយ ។
- មិនត្រូវប្រមូលផ្តុំគ្នា ធ្វើការបញ្ចុះបញ្ចូលក្នុងចេតនាស្វែងរកសម្លេងឆ្នោតនៅក្នុងអគារការិយាល័យរបស់រដ្ឋ ។
- មិនត្រូវចូលរួមសកម្មក្នុងការឃោសនាបោះឆ្នោតសម្រាប់គណបក្សនយោបាយណាមួយឡើយ ។

**សំណួរ ៖ *សកម្មភាពណាខ្លះដែលចាត់ទុកថាជាការជ្រៀតជ្រែក ឬការរារាំង ឬធ្វើឲ្យរំខានរាំងស្ទះដល់សកម្មភាពឃោសនារបស់គណបក្សនយោបាយ បេក្ខជន ឬអ្នកគាំទ្រផ្សេងទៀត ?***

**ចម្លើយ** ៖ សកម្មភាពដែលចាត់ទុកថា ជាការជ្រៀតជ្រែក និងរំខាន រារាំងដល់ការឃោសនារបស់គណបក្សនយោបាយ គឺ ៖

- ការធ្វើទុក្ខទោស លើរាងកាយជនណាមួយ
- ការវាយតប់រាងកាយទៅលើបុគ្គលណាមួយ
- ការបាញ់កាំភ្លើង នៅទីកន្លែងដែលគណបក្សកំពុងធ្វើការឃោសនា ឬកន្លែងប្រជុំ ឬបង្ហើរលើក្បាលអ្នកណាម្នាក់ ឬក៏លើដំបូលផ្ទះអ្នកណាម្នាក់ ឬក៏លើយានយន្តអ្នកណាម្នាក់ ។
- ការរារាំងដោយមធ្យោបាយផ្សេងៗ ដើម្បីបន្ថយបង្អាក់មិនឲ្យក្បួនដង្ហែឃោសនាទៅមុខបាន ឬបញ្ឈប់សកម្មភាពឃោសនាផ្សេងៗទៀត ។
- ការប្រើគ្រឿងផ្ទុះ ដើម្បីរំខានដល់សកម្មភាពឃោសនារបស់គណបក្សនយោបាយ ឬបេក្ខជនកំពុងធ្វើការឃោសនា ឬប្រជុំ ។
- ការទម្លាក់ស្លាករបស់គណបក្សនយោបាយនេះ ក៏ចាត់ទុកជាការរារាំងដល់សកម្មភាពរបស់គណបក្សនយោបាយ ។

**សំណួរ ៖ *ជាចុងក្រោយ តើឯកឧត្តមមានអ្វីដើម្បីបន្ថែមទៀតទេ ?***

**ចម្លើយ** ៖ ជាចុងក្រោយ ខ្ញុំសូមអំពាវនាវដល់គណបក្សនយោបាយ និងបេក្ខជនទាំងអស់ដែលចូលរួមក្នុងការឃោសនាបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់នៅពេលខាងមុខនេះ សូមឲ្យចេះអត់ធ្មត់ គោរពច្បាប់បោះឆ្នោត បទបញ្ជា និងនីតិវិធី និងក្រមសីលធម៌ឲ្យបានម៉ឺងម៉ាត់ ៕

---


## ក្រុមរៀបចំព្រឹត្តិបត្រព័ត៌មាន គ.ជ.ប

**អ្នកគ្រប់គ្រង**

លោក មៃ សារី

**ក្រុមនិពន្ធ**

លោក មិន ពុធជេដ្ឋាវណ្ណ លោក សុខ ឈាន

លោក ទិន ករុណា

**កំណែអក្ខរាវិរុទ្ធ**

អ្នកស្រី ទិន សាវត្តី

**អ្នកថតរូប**

លោក សាក់ បូរិន លោក គីម យុង

លោក រិន វុទ្ធី

**ក្រាហ្វិកកុំព្យូទ័រ**

លោក ប៉េង រតនៈ លោក ចាន់ វិបុល



# យើងយុវវ័យត្រូវទៅបោះឆ្នោតជ្រើសរើស ក្រុមប្រឹក្សាឃុំ សង្កាត់ ឲ្យបានគ្រប់ៗគ្នា

*រៀបរៀងដោយ ៖ នាយកដ្ឋានបណ្តុះបណ្តាល និងព័ត៌មានសាធារណៈនៃ គ.ជ.ប*

*លំនាំបទ : មេឃខ្ពស់ដីទាប*

*ចង្វាក់ :* Bosanova

១- ថ្ងៃសិទ្ធិសេរី ខ្មែរប្រុងប្រៀបប្រាណ បោះឆ្នោតកុំខាន ដើម្បីជាតិយើង
ជាពលរដ្ឋខ្មែរ ថែជាតិឲ្យថ្កើង អភិវឌ្ឍឈានឡើង ដើម្បីកម្ពុជា ។

២- យើងខ្មែរកុំភ្លេច កុំភ្លេចលឿនឡើង រហ័សដៃជើង បបួលគ្នីគ្នា
ប្រជាធិបតេយ្យ ឲ្យទាន់វេលា ឲ្យតម្លៃគ្នា បែបវិមជ្ឈការ ។

៣- បោះដោយសេរី ត្រឹមត្រូវថ្លៃថ្លា គ្រប់ៗអាត្មា បោះដោយស្មើភាព
តាមច្បាប់កំណត់ មានតម្លាភាព បោះតាមរបៀប បោះដោយសម្ងាត់ ។

៤- ត្រូវមានឯកសារ ដោយប្រុងប្រយ័ត្ន ត្រៀមកុំឲ្យបាត់ បញ្ជាក់អត្តសញ្ញាណ
ត្រូវកុំប្រហែស នាំឲ្យខកខាន ឯកសារយើងមាន ប្រើថ្ងៃបោះឆ្នោត ។

៥- បោះឆ្នោតសកល បានផលគ្រប់គ្នា យើងរាស្ត្រប្រជា ត្រូវប្រុងប្រៀបប្រាណ
យើងទៅបោះឆ្នោត កុំឲ្យខកខាន ប្រាំឆ្នាំទៀតបាន ទើបបោះម្តងទៀត ។

( ចប់ )

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត

ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

## លទ្ធផលផ្លូវការនៃការចុះបញ្ជីបេក្ខជននៃគណបក្សនយោបាយឈរឈ្មោះបោះឆ្នោតជ្រើសរើសក្រុមប្រឹក្សាឃុំ សង្កាត់ អាណត្តិទី ៣ ឆ្នាំ ២០១២

| ល.រ | រាជធានី-ខេត្ត | ចំនួនឃុំ/សង្កាត់ (ឃ.ស.) | ចំនួនសមាជិកក្រុមប្រឹក្សា | ចំនួនគណបក្សចុះបញ្ជី | គណបក្សប្រជាជនកម្ពុជា | | | គណបក្សសម រង្ស៊ី | | | គណបក្សហ៊្វុនស៊ិនប៉ិច | | | គណបក្សនរោត្តម រណឫទ្ធិ | | | គណបក្សសិទ្ធិមនុស្ស | | | គណបក្សសម្ព័ន្ធដើម្បីប្រជាធិបតេយ្យ | | | គណបក្សសាធារណរដ្ឋប្រជាធិបតេយ្យ | | | គណបក្សសញ្ជាតិកម្ពុជា | | | គណបក្សសង្គមប្រជាធិបតេយ្យ | | | គណបក្សខ្មែរឈប់ក្រ | | | សរុបតាមរាជធានី-ខេត្ត | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | | | | | ឃ.ស. | បេក្ខជន | ស្រី | ឃ.ស. | បេក្ខជន | ស្រី | ឃ.ស. | បេក្ខជន | ស្រី | ឃ.ស. | បេក្ខជន | ស្រី | ឃ.ស. | បេក្ខជន | ស្រី | ឃ.ស. | បេក្ខជន | ស្រី | ឃ.ស. | បេក្ខជន | ស្រី | ឃ.ស. | បេក្ខជន | ស្រី | ឃ.ស. | បេក្ខជន | ស្រី | ឃ.ស. | បេក្ខជន | ស្រី | បេក្ខជន | ស្រី |
| 01 | បន្ទាយមានជ័យ | 65 | 815 | 8 | 65 | 1,236 | 272 | 65 | 1,104 | 167 | 65 | 1,062 | 224 | 38 | 638 | 183 | 25 | 409 | 142 | 4 | 56 | 12 | 3 | 65 | 31 | | | | | | | 4 | 68 | 6 | 4,638 | 1,037 |
| 02 | បាត់ដំបង | 102 | 814 | 7 | 102 | 2,309 | 584 | 102 | 1,775 | 434 | 100 | 1,676 | 524 | 41 | 748 | 379 | 61 | 1,018 | 393 | 30 | 519 | 168 | | | | | | | | | | 1 | 22 | 11 | 8,067 | 2,493 |
| 03 | កំពង់ចាម | 173 | 1,353 | 9 | 173 | 3,082 | 591 | 173 | 2,840 | 525 | 123 | 1,963 | 654 | 160 | 2,591 | 631 | 173 | 2,777 | 456 | 7 | 133 | 49 | | | | 63 | 1,039 | 508 | 2 | 24 | 9 | 1 | 14 | 2 | 14,463 | 3,425 |
| 04 | កំពង់ឆ្នាំង | 69 | 419 | 9 | 69 | 1,001 | 216 | 69 | 981 | 165 | 69 | 876 | 251 | 69 | 941 | 252 | 69 | 880 | 181 | 2 | 24 | 6 | 2 | 24 | 14 | 6 | 73 | 44 | | | | 1 | 10 | 2 | 4,790 | 1,131 |
| 05 | កំពង់ស្ពឺ | 87 | 609 | 8 | 87 | 1,391 | 250 | 87 | 1,373 | 208 | 77 | 1,112 | 283 | 78 | 1,142 | 248 | 86 | 1,238 | 151 | 18 | 285 | 76 | | | | 9 | 125 | 75 | | | | 5 | 70 | 26 | 6,736 | 1,319 |
| 06 | កំពង់ធំ | 81 | 677 | 9 | 81 | 1,338 | 270 | 81 | 1,230 | 222 | 80 | 1,185 | 289 | 71 | 1,086 | 398 | 42 | 669 | 174 | 4 | 76 | 30 | 1 | 22 | 11 | 19 | 262 | 130 | | | | 4 | 44 | 18 | 5,912 | 1,542 |
| 07 | កំពត | 93 | 561 | 8 | 93 | 1,352 | 258 | 93 | 1,263 | 197 | 80 | 967 | 300 | 56 | 741 | 225 | 68 | 918 | 175 | 2 | 25 | 9 | 1 | 10 | 3 | | | | | | | 1 | 10 | 2 | 5,286 | 1,169 |
| 08 | កណ្ដាល | 127 | 915 | 8 | 127 | 2,079 | 473 | 127 | 2,029 | 397 | 99 | 1,433 | 548 | 59 | 931 | 342 | 127 | 1,952 | 326 | 10 | 179 | 80 | | | | 47 | 603 | 377 | | | | 3 | 46 | 19 | 9,452 | 2,582 |
| 09 | កោះកុង | 29 | 167 | 6 | 29 | 392 | 86 | 26 | 329 | 100 | 15 | 194 | 67 | 8 | 113 | 38 | | | | 1 | 10 | 4 | | | | | | | | | | | | | 1,038 | 315 |
| 10 | ក្រចេះ | 46 | 282 | 6 | 46 | 735 | 200 | 46 | 612 | 124 | 46 | 638 | 175 | 33 | 423 | 126 | 37 | 475 | 177 | | | | | | | 6 | 61 | 19 | | | | | | | 2,944 | 821 |
| 11 | មណ្ឌលគិរី | 21 | 107 | 5 | 21 | 275 | 45 | 21 | 228 | 64 | 19 | 198 | 55 | 1 | 10 | 5 | 1 | 14 | 3 | | | | | | | | | | | | | | | | 728 | 172 |
| 12 | ភ្នំពេញ | 96 | 810 | 8 | 96 | 1,873 | 578 | 96 | 1,775 | 597 | 75 | 1,244 | 630 | 40 | 630 | 282 | 65 | 1,105 | 399 | 1 | 25 | 15 | | | | 10 | 186 | 119 | | | | 1 | 10 | 1 | 6,848 | 2,621 |
| 13 | ព្រះវិហារ | 51 | 333 | 6 | 51 | 790 | 194 | 51 | 789 | 150 | 46 | 631 | 158 | 8 | 116 | 39 | 11 | 163 | 66 | | | | | | | | | | | | | | | | 2,489 | 607 |
| 14 | ព្រៃវែង | 116 | 892 | 8 | 116 | 1,934 | 589 | 116 | 1,901 | 300 | 89 | 1,414 | 505 | 105 | 1,657 | 420 | 116 | 1,844 | 206 | 17 | 292 | 97 | 1 | 10 | 3 | 52 | 849 | 447 | | | | | | | 9,901 | 2,567 |
| 15 | ពោធិ៍សាត់ | 49 | 343 | 6 | 49 | 857 | 195 | 47 | 684 | 217 | 44 | 647 | 255 | 27 | 418 | 114 | 15 | 215 | 67 | 3 | 51 | 20 | | | | | | | | | | | | | 2,872 | 868 |
| 16 | រតនគិរី | 50 | 260 | 4 | 50 | 616 | 112 | 38 | 441 | 121 | 32 | 341 | 99 | 2 | 22 | 8 | | | | | | | | | | | | | | | | | | | 1,422 | 340 |
| 17 | សៀមរាប | 100 | 668 | 7 | 100 | 1,558 | 281 | 100 | 1,513 | 284 | 100 | 1,418 | 289 | 75 | 1,062 | 360 | 25 | 335 | 120 | 57 | 906 | 145 | | | | 2 | 45 | 25 | | | | | | | 6,837 | 1,604 |
| 18 | ព្រះសីហនុ | 27 | 169 | 5 | 27 | 369 | 65 | 27 | 342 | 42 | 25 | 328 | 86 | 15 | 227 | 74 | 2 | 21 | 12 | | | | | | | | | | | | | | | | 1,287 | 279 |
| 19 | ស្ទឹងត្រែង | 34 | 176 | 4 | 34 | 430 | 87 | 34 | 408 | 107 | 20 | 239 | 62 | 14 | 163 | 53 | | | | | | | | | | | | | | | | | | | 1,240 | 309 |
| 20 | ស្វាយរៀង | 80 | 618 | 7 | 80 | 1,171 | 240 | 79 | 1,065 | 279 | 77 | 1,006 | 350 | 51 | 724 | 231 | 40 | 574 | 135 | | | | | | | 5 | 59 | 31 | | | | 2 | 40 | 21 | 4,639 | 1,287 |
| 21 | តាកែវ | 100 | 736 | 8 | 100 | 1,655 | 336 | 100 | 1,624 | 295 | 100 | 1,568 | 361 | 61 | 1,004 | 272 | 94 | 1,440 | 214 | 5 | 94 | 30 | 1 | 10 | 4 | 6 | 69 | 41 | | | | | | | 7,484 | 1,653 |
| 22 | កែប | 5 | 31 | 3 | 5 | 79 | 17 | 5 | 63 | 24 | 3 | 38 | 13 | | | | | | | | | | | | | | | | | | | | | | 180 | 54 |
| 23 | ប៉ៃលិន | 8 | 52 | 4 | 8 | 134 | 39 | 8 | 124 | 41 | 5 | 66 | 20 | 4 | 61 | 27 | | | | | | | | | | | | | | | | | | | 385 | 127 |
| 24 | ឧត្តរមានជ័យ | 24 | 162 | 6 | 24 | 353 | 91 | 24 | 308 | 86 | 24 | 308 | 88 | 15 | 222 | 45 | 13 | 192 | 64 | 3 | 38 | 5 | | | | | | | | | | | | | 1,421 | 379 |
| | សរុប | 1,633 | 11,459 | 10 | 1,633 | 27,011 | 6,069 | 1,615 | 24,601 | 5,146 | 1,413 | 20,552 | 6,306 | 1,029 | 16,670 | 4,752 | 1,070 | 16,219 | 3,461 | 164 | 2,713 | 746 | 9 | 141 | 66 | 225 | 3,591 | 1,816 | 2 | 24 | 9 | 23 | 334 | 110 | 111,056 | 28,481 |

រាជធានីភ្នំពេញ ថ្ងៃទី ២៣ ខែមេសា ឆ្នាំ ២០១២